# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ១៩
ចុះថ្ងៃទី២៦-០១-២០១២
សាលដីកា
លេខ: ៨៦ ក្រ៥.ប
ចុះថ្ងៃទី ០៥-៧-២០១៣

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍

បានបង្កើតឡើងតាមច្បាប់ ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍ នាថ្ងៃទី២៧-៦-២០១៣ ដោយមានសមាសភាពដូចខាងក្រោម៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធាន
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

- លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

- លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃរឿងព្រហ្មទណ្ឌលេខ ១៩ ចុះថ្ងៃទី ២៦-០១-២០១២ រវាង:

- ជនជាប់ចោទ:

១- ឈ្មោះ [redacted] ជា ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតភូមិឈើទាល ឃុំឈូក ស្រុកឈូក ខេត្តកំពត ទីលំនៅផ្ទះជួល [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (ស) ទោសពីមុនគ្មាន ។ ឃុំខ្លួន ថ្ងៃទី១២-៣-២០១១ (ម$_{១}$) ។

២- ឈ្មោះ [redacted] ម៉ាប់ ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករសំណង់ ទីកន្លែងកំណើតភូមិស្វាយអញ្ចិត ឃុំស្វាយអញ្ចិត ស្រុកជុំគិរី ខេត្តកំពត ទីលំនៅផ្ទះជួល [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ទោសពីមុនគ្មាន ។ ឃុំខ្លួន ថ្ងៃទី១២-៣-២០១១ (ម$_{១}$) ។

ត្រូវជាប់ចោទពីបទ: អំពើលួចមានស្ថានទម្ងន់ទោសដោយសារប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៣-៣-/



Scanned with CamScanner

២០១១ បទល្មើសព្រហ្មទណ្ឌដែលមានត្រូវផ្តន្ទាទោសតាមមាត្រា ៣៥៣ និង៣៥៧ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

៣- ឈ្មោះ [redacted] ធី ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករសំណង់ ទីកន្លែងកំណើតភូមិស្វាយអញ្ចិត ឃុំស្វាយអញ្ចិត ស្រុកជុំគិរី ខេត្តកំពត ទីលំនៅផ្ទះជួល ផ្លូវលំ [redacted] ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] ។ ឃុំខ្លួន ថ្ងៃទី១២-៣-២០១១ (ម១) ។

ត្រូវជាប់ចោទពីបទ: អំពើទទួលផលចោរកម្ម ប្រព្រឹត្តនៅភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៣-៣-២០១១ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

- ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ៣៥ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅផ្ទះជួល [redacted] ។

- តាមបណ្តឹងឧទ្ធរណ៍លេខ ៧៨១ ចុះថ្ងៃទី១៦-១១-២០១១ របស់ឈ្មោះ [redacted] ជា នឹងសាលក្រមព្រហ្មទណ្ឌលេខ ១២៤ ក្រ៦ប ចុះថ្ងៃទី០៨-១១-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច សេចក្តីសម្រេចទាំងមូល ។

- តាមបណ្តឹងឧទ្ធរណ៍លេខ ៨៤៥ ចុះថ្ងៃទី០៦-១២-២០១១ របស់លោក [redacted] វាសនា មេធាវីទទួលសិទ្ធិប្តឹងឧទ្ធរណ៍ពីឈ្មោះ [redacted] ធី, ឈ្មោះ [redacted] ម៉ាប់ នឹងសាលក្រមព្រហ្មទណ្ឌលេខ ១២៤ ក្រ៦ប ចុះថ្ងៃទី០៨-១១-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច សេចក្តីសម្រេចទាំងមូល ។

**<u>ឯរឿងហេតុមានដូចតទៅ:</u>**

កាលពីថ្ងៃទី០៣-៣-២០១១ វេលាម៉ោងប្រហែល ១០ព្រឹក ជនជាប់ចោទឈ្មោះ [redacted] ជា និងជនជាប់ចោទឈ្មោះ [redacted] ម៉ាប់ បានធ្វើដំណើរដោយរួមគ្នាហើយធ្វើសកម្មភាពលួចកាច់សោរកម៉ូតូរបស់ជនរងគ្រោះឈ្មោះ [redacted] សារុំ ដែលបានចតទុកចោលនៅភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។ បន្ទាប់ពីលួចយកម៉ូតូរបស់ជនរងគ្រោះបាន ហើយជនជាប់ចោទឈ្មោះ [redacted] ជា បានយកម៉ូតូនោះទៅលក់ឲ្យឈ្មោះ ខន ក្នុងតម្លៃ ៧០០ ដុល្លាអាមេរិក ហើយបានយកប្រាក់មកចែកគ្នាដោយក្នុងនោះក៏មានចំណែកជនជាប់ចោទឈ្មោះ [redacted] ធី ចំនួន ២០០ ដុល្លាអាមេរិកផងដែរ ។ លុះដល់ថ្ងៃទី០៩-៣-២០១១ ជនជាប់ចោទក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។

- បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១២៤ ក្រ៦ប ចុះថ្ងៃទី០៨-១១-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចថា:

១- ផ្តន្ទាទោសលើ: ៧៧៤



Scanned with CamScanner

ក- ឈ្មោះ [redacted] ជា ភេទប្រុស អាយុ២៩ឆ្នាំ ។

ខ- ឈ្មោះ [redacted] ម៉ាប់ ភេទប្រុស អាយុ១៩ឆ្នាំ ។

ដាក់ពន្ធនាគារក្នុងម្នាក់ៗ ០៥ឆ្នាំ (ប្រាំឆ្នាំ) ។

ពីបទ: អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ។

គ- ឈ្មោះ [redacted] ធី ភេទប្រុស អាយុ២៥ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០២ឆ្នាំ (ពីរឆ្នាំ) ។

ពីបទ: អំពើទទួលផលចោរកម្ម ។

ប្រព្រឹត្តនៅភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៣-៣-២០១១ ។ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា ៩៧ និងមាត្រា ៣៥៧ និង មាត្រា ៤០០ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

២- បង្គាប់ឲ្យឈ្មោះ [redacted] ជា និងឈ្មោះ [redacted] ម៉ាប់ និងឈ្មោះ [redacted] ធី រួមគ្នាសងសំណងរដ្ឋប្បវេណីចំនួន ៦.០០០.០០០រៀល (ប្រាំមួយលានរៀល) ឲ្យទៅឈ្មោះ [redacted] សារុំ ការទាមទារលើសពីនេះបដិសេធចោល ។ តាមបញ្ញត្តិមាត្រា ២៣ និងមាត្រា ៣៥៥ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

៣- វត្ថុចាប់យកនូវ: ស្លាកលេខម៉ូតូមួយបន្ទះ លេខភ្នំពេញ 1AR-4752 ។ ត្រូវរឹបអូសបំផ្លាញចោល ។

៤- សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ជា និង ជនជាប់ចោទឈ្មោះ [redacted] ម៉ាប់ និងជនជាប់ចោទឈ្មោះ [redacted] ធី និងកំបាំងមុខជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ។ ទុករយៈពេលប្តឹងទាស់ និងបើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

- បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៧៨១ ចុះថ្ងៃទី១៦-១១-២០១១ របស់ឈ្មោះ [redacted] ជា នឹងសាលក្រមព្រហ្មទណ្ឌលេខ ១២៤ ក្រ៦ប ចុះថ្ងៃទី០៨-១១-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច សេចក្តីសម្រេចទាំងមូលនៃសាលក្រម ។

- បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៨៥៥ ចុះថ្ងៃទី០៦-១២-២០១១ របស់លោក [redacted] វាសនា មេធាវីទទួលសិទ្ធិប្តឹងឧទ្ធរណ៍ពីឈ្មោះ [redacted] ធី, ឈ្មោះ [redacted] ម៉ាប់ នឹងសាលក្រមព្រហ្មទណ្ឌលេខ ១២៤ ក្រ៦ប ចុះថ្ងៃទី០៨-១១-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច សេចក្តីសម្រេចទាំងមូលនៃសាលក្រម ។

- បានឃើញ របាយការណ៍រឿង ចុះថ្ងៃទី០៦-៤-២០១២ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

- បានឃើញ សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី០៨-៤-២០១៣ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។/

៧២៥



Scanned with CamScanner

VSK

## នាពេលសវនាការ

- ជនជាប់ចោទឈ្មោះ [redacted] ជា, [redacted] ធី, [redacted] ម៉ាប់ (វត្តមាន)

- មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទលោក [redacted] ម៉ាច (វត្តមាន)

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] (អវត្តមាន)

ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបរឿង

- ជនជាប់ចោទឈ្មោះ [redacted] ជា បានឆ្លើយថា ខ្លួនប្តឹងឧទ្ធរណ៍មកនេះសុំឲ្យតុលាការបន្ធូរបន្ថយទោសឲ្យខ្លួនផង ។

- ជនជាប់ចោទឈ្មោះ [redacted] ម៉ាប់ និងឈ្មោះ [redacted] ធី បានឆ្លើយដូចគ្នាថា ខ្លួនទទួលស្គាល់កំហុសហើយ ប៉ុន្តែសុំឲ្យតុលាការបន្ធូរបន្ថយទោសឲ្យខ្លួនផង ។

## តំណាងមហាអយ្យការសន្និដ្ឋានថា:

តាមចម្លើយជនជាប់ចោទបានសារភាពទទួលកំហុស ហើយសុំបន្ធូរបន្ថយទោស ។ សុំក្រុមប្រឹក្សាមេត្តាពិនិត្យ ពិចារណា តាមច្បាប់ ។

## មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទសន្និដ្ឋានថា:

- លោក [redacted] ម៉ាច មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទសន្និដ្ឋានថា សុំឲ្យតុលាការដោះលែងជនជាប់ចោទដែលជាកូនក្តីខ្លួននេះ ព្រោះជនជាប់ចោទបានទទួលស្គាល់កំហុសរបស់ខ្លួនដែលបានប្រព្រឹត្ត ។

- ក្រោយពីបានស្តាប់អំណានរបាយការណ៍រឿង
- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសន្និដ្ឋាន
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
- ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាឧទ្ធរណ៍យល់ឃើញថា:

១- បណ្តឹងឧទ្ធរណ៍លេខ ៧៨១ ចុះថ្ងៃទី១៦-១១-២០១១ របស់ជនជាប់ចោទឈ្មោះ ខាន់ ជា និងបណ្តឹងឧទ្ធរណ៍លេខ ៨៩៥ ចុះថ្ងៃទី០៦-១២-២០១១ របស់មេធាវីទទួលសិទ្ធិពីជនជាប់ចោទឈ្មោះ [redacted] ធី និងឈ្មោះ [redacted] ម៉ាប់ បណ្តឹងនេះធ្វើឡើងក្នុងកំណត់ច្បាប់ យោងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន ។

២- តាមអង្គហេតុករណីជនរងគ្រោះឈ្មោះ [redacted] សារុំ ពិតជាបានបាត់ម៉ូតូម៉ាក C-125 ពណ៌ខ្មៅ នៅភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៣-៣-២០១១ ត្រូវបានសមត្ថកិច្ចសង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ សង្ស័យលើឈ្មោះ [redacted] ជា និងឈ្មោះ [redacted] ម៉ាប់ ជាអ្នកប្រព្រឹត្ត ហើយជិះយកមកលក់ឲ្យឈ្មោះ [redacted] ធី ពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌខាងលើ ហើយឃាត់ខ្លួន ថ្ងៃទី១២-៣-២០១១ ។

៣- នៅគ្រប់នីតិវិធីស៊ើបអង្កេតរបស់តុលាការក៏ដូចជានៅពេលសវនាការសាលាឧទ្ធរណ៍ជនជាប់ចោទបានឆ្លើយសារភាពថា ពួកខ្លួន ([redacted] ជា និង [redacted] ម៉ាប់) ពិតជាបាន



Scanned with CamScanner

លួចម៉ូតូម៉ាក សេ១២៥ ពណ៌ខ្មៅរបស់ជនរងគ្រោះឈ្មោះ [redacted] សារុំ ហើយយកឈ្មោះ [redacted]ធី ជាអ្នកទទួលទិញប្រាកដមែន ។

៤- ជនជាប់ចោទបានទទួលស្គាល់អង្គហេតុខាងលើ ហើយប្តឹងឧទ្ធរណ៍មកនេះក្នុងបំណងសុំឲ្យមានការបន្ធូរបន្ថយទោស សំណើនេះសាលាឧទ្ធរណ៍គប្បីលើកមកពិចារណា

៥- តាមអង្គហេតុជនជាប់ចោទបានទទួលស្គាល់ការប្រព្រឹត្តរបស់ខ្លួនប្រាកដមែន ប៉ុន្តែសកម្មភាពប្រព្រឹត្តរបស់ជនជាប់ចោទពុំបានគាស់ទំលុះទំលាយ ឬប្រើហិង្សាទៅលើជនរងគ្រោះ ឬអ្នកដទៃឲ្យមានរបួស ឬស្លាប់ឡើយ ពោលគឺគ្រាន់តែផ្តាច់ខ្សែកុងតាក់រួចជិះចេញពីមុខផ្ទះជនរងគ្រោះ ទាំងជនរងគ្រោះខ្លួនឯងក៏ពុំបានដឹងដែរ ដូច្នេះសកម្មភាពបែបនេះមិនអាចដាក់ឲ្យជនជាប់ចោទឈ្មោះ ខាន់ ជា និងឈ្មោះ គុណ ម៉ាប់ ទទួលខុសត្រូវ ក្នុងបទចោទប្រកាន់ពីបទៈ លួចដោយមានស្ថានទម្ងន់ទោស ដោយសារប្រព្រឹត្តអំពើហិង្សាឡើយ គឺអំពើលួចធម្មតាដែលមានចែងក្នុងមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

៦- មានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] ជា, ឈ្មោះ [redacted] ម៉ាប់ និងឈ្មោះ [redacted] ធី ពីបទ លួចទ្រព្យអ្នកដទៃ មកជាបទ ទទួលផលចោរកម្ម ប្រព្រឹត្តនៅភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៣-៣-២០១១ តាមបញ្ញត្តិមាត្រា ៣៥៣, ៣៥៦ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ ។

៧- សាលក្រមព្រហ្មទណ្ឌលេខ ២៤ (ក្រ៦ប) ចុះថ្ងៃទី០៨-១១-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ គួរតម្កល់ទុកជាបានការលើកលែងតែទណ្ឌកម្មលើជនជាប់ចោទឈ្មោះ [redacted] ជា និងឈ្មោះ [redacted] ម៉ាប់ គួរកែប្រែតាមការយល់ឃើញខាងលើ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៧៨១ ចុះថ្ងៃទី១៦-១១-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted]ជា និងបណ្តឹងឧទ្ធរណ៍លេខ ៨៤៥ ចុះថ្ងៃទី០៦-១២-២០១១ របស់មេធាវីទទួលសិទ្ធិពីជនជាប់ចោទឈ្មោះ [redacted]ធី និងឈ្មោះ [redacted]ម៉ាប់ ទុកជាត្រឹមត្រូវតាមច្បាប់ ។

- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៨៤៥ ចុះថ្ងៃទី០៦-១២-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] ធី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១២៤ ក្រ៦.ប ចុះថ្ងៃទី០៨-១១-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែទណ្ឌកម្មលើជនជាប់ចោទឈ្មោះ [redacted] ជា និងជនជាប់ចោទឈ្មោះ [redacted] ម៉ាប់ ត្រូវកែប្រែពីដាក់ពន្ធនាគារម្នាក់ៗកំណត់ ៥ឆ្នាំ មកជា ដាក់ពន្ធនាគារម្នាក់ៗកំណត់ ៣ឆ្នាំវិញ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ចំណុចក្រៅពីនេះរក្សាទុកដដែល ។/.



Scanned with CamScanner

៣- បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។

៤- សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៧-៦-២០១៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ជា, [redacted] ម៉ាប់ និង [redacted] ធី និងមេធាវីការពារជនជាប់ចោទ កំបាំងមុខជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណី ប្រកាសជាសាធារណៈ ថ្ងៃទី០៥-៧-២០១៣ ។

- បើកផ្លូវប្ដឹងតវ៉ាតាមកំណត់ច្បាប់ ។

សាលដីកានេះបានចូលជាស្ថាពរ និងមានអានុភាពអនុវត្តទៅលើឈ្មោះ គុណ ម៉ាប់ តែប៉ុណ្ណោះ ក្រៅពីនេះពុំមានអានុភាពទេ ។

សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុក អនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធជួយ សហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

---

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី...... ខែ...... ឆ្នាំ ២០១...
ក្រឡាបញ្ជី
[redacted]





Scanned with CamScanner